**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦.០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើត ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ ចុះថ្ងៃទី ២៣ ខែមិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និង គ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- យោងតាមសំណើរបស់ក្រសួងអប់រំ យុវជន និង កីឡា

## សម្រេច

**មាត្រា ១** : អនុញ្ញាតអោយបង្កើត គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា " ស.ប.ស.ក " ។ សាកលវិទ្យាល័យនេះមានទីតាំងគោលនៅផ្ទះលេខ ១០ ផ្លូវ ២១៤ (សម្តេចប៉ាន) សង្កាត់ជ័យជំនះ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ និងមានសាខាពីរកន្លែងផ្សេងទៀតគឺ :

- សាខាទី១ :ស្ថិតនៅអាគារលេខ០៦ វិថីសម្តេចប៉ាន់ សង្កាត់ជ័យជំនះ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ។

- សាខាទី២ :ស្ថិតនៅអាគារលេខ ៥៥ វិថី សម្តេចប៉ាន់ សង្កាត់បឹងរាំង ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ។

**មាត្រា ២ :** សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជាមាន ០៦ មហាវិទ្យាល័យ និងវិទ្យាស្ថានមួយ

១. មហាវិទ្យាល័យសិល្បៈ និង អក្សរសាស្ត្រ

២. មហាវិទ្យាល័យពាណិជ្ជសាស្ត្រ និងសេដ្ឋសាស្ត្រ

៣. មហាវិទ្យាល័យកិច្ចការសាធារណៈ និងអន្តរជាតិ

៤. មហាវិទ្យាល័យវិទ្យាសាស្ត្រ និងវិស្វកម្ម

៥. មហាវិទ្យាល័យអប់រំ

៦. មហាវិទ្យាល័យសិល្បៈ ផ្សព្វផ្សាយពត៌មានវិជ្ជា

៧. វិទ្យាស្ថានភាសាបរទេស

ទៅថ្ងៃអនាគត សាកលវិទ្យាល័យអាចបើកជំនាញឯកទេសផ្សេងៗទៀត និង សាលាជំនាញទៀត ដោយរៀបចំសុំណុំបែបបទ សុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៣ :** សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជាមានបីកំរិតគឺ ថ្នាក់បរិញ្ញាប័ត្រ ថ្នាក់ម៉ាស្ទ័រ និង ថ្នាក់បណ្ឌិត

១.ថ្នាក់បរិញ្ញាប័ត្រ :មានរយៈពេលសិក្សាយ៉ាងតិច ៤ឆ្នាំ ដែលមានចំនួនក្រេឌីតយ៉ាងតិច ១២៨ ក្រេឌីត

២.ថ្នាក់ម៉ាស្ទ័រ : មានរយៈពេលសិក្សាយ៉ាងតិច ២ឆ្នាំ ដែលមានចំនួនក្រេឌីតយ៉ាងតិច៤២ក្រេឌីត

៣.ថ្នាក់បណ្ឌិត : មានរយៈពេលសិក្សាយ៉ាងតិច ៣ឆ្នាំដែលមានចំនួនក្រេឌីតយ៉ាងតិច ៥៤ក្រេឌីត

**មាត្រា ៤ :** លក្ខខណ្ឌទទួលសិស្សអោយចូលរៀន :

១- ថ្នាក់បរិញ្ញាប័ត្រ : បេក្ខជនទាំងពីរភេទ មានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ រឺ សញ្ញាប័ត្រដែលមានតំលៃស្មើ ។

២- ថ្នាក់ម៉ាស្ទ័រ : បេក្ខជនទាំងពីរភេទ មានសញ្ញាប័ត្របរិញ្ញាប័ត្រ រឺសញ្ញាប័ត្រដែលមានតំលៃស្មើ ។

៣- ថ្នាក់បណ្ឌិត : បេក្ខជនទាំងពីរភេទ មានសញ្ញាប័ត្រ ថ្នាក់ម៉ាស្ទ័រ ឬ សញ្ញាប័ត្រដែលមានតំលៃស្មើ ។

៤- បេក្ខជនត្រូវឆ្លងកាត់ការប្រលងតេស្ត ។

**មាត្រា ៥ :** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជាមានភារកិច្ច :

- ជ្រើសរើសសិស្ស និស្សិតអោយចូលរៀន និង ជ្រើសរើស សាស្ត្រាចារ្យមកបង្រៀន ។
- គ្រប់គ្រងអោយបានល្អ នូវការបង្រៀន ការងារស្រាវជ្រាវ ឯកសារសិក្សា ការប្រលង និង ការប្រគល់សញ្ញាប័ត្រ ។
- គោរព និង អនុវត្ត តាមសារាចរ និង សេចក្តីណែនាំ របស់រាជរដ្ឋាភិបាល ។
- ធានាអោយបាន នូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។
- ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សាជូនក្រសួង អប់រំ យុវជន និង កីឡា រៀងរាល់ ឆមាស ។

**មាត្រា ៦ :** សាកលវិទ្យាល័យមានក្រុមប្រឹក្សាភិបាលមួយ ទទួលបន្ទុកគ្រប់គ្រងសាកលវិទ្យាល័យនេះ និងមានក្រុមប្រឹក្សាបណ្ឌិតសភាមួយ មានសមាជិកប្រាំរូបដែលមានសញ្ញាប័ត្រកិត្តិបណ្ឌិត សំរាប់ពិនិត្យ និងផ្តល់យោបល់ លើកម្មវិធីសិក្សានៅដើមឆ្នាំនីមួយៗ ។

**មាត្រា ៧ :** ក្រសួងអប់រំ យុវជន និងកីឡា មានសិទ្ធិធ្វើអធិការកិច្ច និងត្រួតពិនិត្យលើការងារបណ្តុះបណ្តាល ហើយមានសិទ្ធិស្នើសុំបិទ ប្រសិនបើសាកលវិទ្យាល័យនេះអនុវត្តខុសពីច្បាប់រដ្ឋ។

**មាត្រា ៨ :** និស្សិត ដែលរៀនចប់កម្មវិធីសិក្សា របស់សាកលវិទ្យាល័យនេះ និងទទួលបានជោគជ័យក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវបានទទួលសញ្ញាប័ត្របរិញ្ញាប័ត្រ , ម៉ាស្ទ័រ និង បណ្ឌិតដែលផ្តល់អោយដោយសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីសាកលវិទ្យាល័យនេះ បានបំពេញនិងអនុវត្តតាមនិយាមអប្បបរមា នៃការទទួលស្គាល់គុណភាពអប់រំថ្នាក់ឧត្តមសិក្សា ។

**មាត្រា ៩ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួង អប់រំ យុវជន និង កីឡា អគ្គនាយកដ្ឋានអង្គភាពពាក់ព័ន្ធ និង សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា មានភារកិច្ចរៀងៗខ្លួន ដើម្បីអនុវត្ត និងប្រតិបត្តិ តាមអនុក្រឹត្យនេះ ។

**មាត្រា ១០ :** អនុក្រឹត្យនេះ មានប្រសិទ្ធិភាព និង គតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាក្រុងភ្នំពេញ

"ដើម្បីជូនដំណឹង"

- ដូចមាត្រា ៩ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ